**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងរដ្ឋប្បវេណីលេខៈ ៦៩៦
ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣
សញ្ញាណរឿងក្តី៖បណ្តឹងទាក់ទងនឹងវិវាទគ្រួសារ
សាលក្រមរដ្ឋប្បវេណីលេខៈ ០១៩ /យ៉
ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤

## តាមនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្តាល បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ។

## ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តកណ្តាល

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

## សាលាដំបូងខេត្តកណ្តាល

សាលាដំបូងខេត្តកណ្តាល បានចេញសាលក្រមដែលមានគូភាគីដូចខាងក្រោម:

-ដើមចោទ(ចុងចម្លើយនៃបណ្តឹងតប)ឈ្មោះ [redacted] ម៉ាលីស ភេទស្រី កើតឆ្នាំ១៩៨៤ អាស័យដ្ឋាន [redacted]។

តំណាងដោយអាណត្តិ៖ លោកស្រី [redacted]

-ចុងចម្លើយ(ដើមចោទនៃបណ្តឹងតប) ឈ្មោះ [redacted] វាសនា មានទីលំនៅបច្ចុប្បន្ន [redacted]

តំណាងដោយអាណត្តិ៖លោក [redacted]

កម្មវត្ថុ: បណ្តឹងទាក់ទងនឹងវិវាទគ្រួសារដែលមិនបានចុះបញ្ជី

## អង្គហេតុ និងចំណុចវិវាទ

១. ការពន្យល់ត្រួសៗអំពីរឿងក្តី

ដើមចោទឈ្មោះ [redacted] ម៉ាលីស និងចុងចម្លើយឈ្មោះ [redacted] វាសនា បានរៀបការតាមប្រពៃណីតាំងពីឆ្នាំ២០១៥ ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ឡើយ ។ ក្នុងការរស់នៅមិនចុះសម្រុងនឹងគ្នា ចេះតែមានបញ្ហារកាំរកូស មិនចេះចប់រហូតអស់មនោសញ្ចេតនាជាប្តីប្រពន្ធ ទើបដើមចោទដាក់ពាក្យស្នើសុំមកតុលាការដើម្បីសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិរួមតែម្តង ។ ក្រោយការរួមរស់ជាមួយគ្នា ដើមចោទ និងចុងចម្លើយគ្មានកូនទេ ប៉ុន្តែដើមចោទ និងចុងចម្លើយមានទ្រព្យសម្បត្តិរួមដូចខាងក្រោម៖

– ដី និងផ្ទះល្វែង ១ ល្វែង ទទឹងប្រវែង ៣ ម៉ែត្រ និងបណ្តោយប្រវែង ១៦ ម៉ែត្រ មានវិញ្ញាបនបត្រសម្គាល់



Scanned with CamScanner

ម្ចាស់អចលនវត្ថុលេខ ០៨១១០៥០១-០៥៣០ ចុះថ្ងៃទី ១២ ខែតុលា ឆ្នាំ២០២១ ចេញដោយសុរិយោដីខេត្តកណ្តាល ទីតាំងស្ថិតនៅភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល។

– ម៉ូតូម៉ាក PCX សេរី ២០១១ ពាក់ស្លាកលេខ 1IE-3697 ចំនួន ០១ គ្រឿង ។

– កុំព្យូទ័រម៉ាក DELL ចំនួន ០១ គ្រឿង

– សម្ភារៈក្នុងផ្ទះ រួមមាន ម៉ាស៊ីនត្រជាក់ ០១ គ្រឿង ទូរទឹកកក ០១ គ្រឿង ម៉ាស៊ីនបោកខោអាវ ០១ គ្រឿង និងគ្រែឈើ រួមទាំងរបស់របរផ្សេងៗទៀត ។

– តូបដែលមានទីតាំងនៅផ្សារសៀមរាប ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

២. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

ដើមចោទ និងចុងចម្លើយជាប្តីប្រពន្ធដែលមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ស្របច្បាប់។ ដោយមិនអាចបន្តរស់នៅជាមួយចុងចម្លើយជាប្តីប្រពន្ធនឹងគ្នាទៀតបាន ក៏បានបែកលំនៅគ្នា ប៉ុន្តែដោយសារមានពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរួមគ្នា ទើបភាគីដើមចោទដាក់ពាក្យបណ្តឹងមកតុលាការស្នើសុំបែងចែកទ្រព្យសម្បត្តិរួម ។

៣. សាលក្រមដែលទាមទារដោយដើមចោទ

ប្តឹងសុំបែងចែកទ្រព្យសម្បត្តិជាពីរចំណែកស្មើគ្នា នូវទ្រព្យសម្បត្តិរួមដូចខាងក្រោម ៖

- ដី និងផ្ទះល្វែង ១ ល្វែង ទទឹងប្រវែង ៣ ម៉ែត្រ និងបណ្តោយប្រវែង ១៦ ម៉ែត្រ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១១០៥០១-០៥៣០ ចុះថ្ងៃទី ១២ ខែតុលា ឆ្នាំ២០២១ ចេញដោយសុរិយោដីខេត្តកណ្តាល ទីតាំងស្ថិតនៅភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល។

- ម៉ូតូម៉ាក PCX សេរី ២០១១ ពាក់ស្លាកលេខ 1IE-3697 ចំនួន ០១ គ្រឿង ។

- កុំព្យូទ័រម៉ាក DELL ចំនួន ០១ គ្រឿង

- សម្ភារៈក្នុងផ្ទះ រួមមាន ម៉ាស៊ីនត្រជាក់ ០១ គ្រឿង ទូរទឹកកក ០១ គ្រឿង ម៉ាស៊ីនបោកខោអាវ ០១ គ្រឿង និងគ្រែឈើ រួមទាំងរបស់របរផ្សេងៗទៀត ។

- តូបដែលមានទីតាំងនៅផ្សារសៀមរាប ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

៤. ការអះអាងរបស់ដើមចោទ

ដើមចោទឈ្មោះ [redacted] ម៉ាលីស បានអះអាងថា: ខ្លួន និងប្តីឈ្មោះ [redacted] វាសនា បានរៀបការតាមប្រពៃណីតាំងពីឆ្នាំ២០១៥ ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ឡើយ ។ ក្នុងការរស់នៅមិនចុះសម្រុងនឹងគ្នា ចេះតែមានបញ្ហារកាំរកូស មិនចេះចប់រហូតអស់មនោសញ្ចេតនាជាប្តីប្រពន្ធ ទើបខ្លួនដាក់ពាក្យស្នើសុំមកតុលាការដើម្បីសម្រេចអំពីការបែងចែកទ្រព្យសម្បត្តិរួមតែម្តង ។ ក្រោយការរួមរស់ជាមួយគ្នា ខ្លួន និងប្តីគ្មានកូនទេ ប៉ុន្តែខ្លួន និងប្តីឈ្មោះ [redacted] វាសនា មានទ្រព្យសម្បត្តិរួមដូចខាងក្រោម៖

– ដី និងផ្ទះល្វែង ១ ល្វែង ទទឹងប្រវែង ៣ ម៉ែត្រ និងបណ្តោយប្រវែង ១៦ ម៉ែត្រ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១១០៥០១-០៥៣០ ចុះថ្ងៃទី ១២ ខែតុលា ឆ្នាំ២០២១ ចេញដោយសុរិយោដីខេត្តកណ្តាល ទីតាំងស្ថិតនៅភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល។

– ម៉ូតូម៉ាក PCX សេរី ២០១១ ពាក់ស្លាកលេខ 1IE-3697 ចំនួន ០១ គ្រឿង ។

– កុំព្យូទ័រម៉ាក DELL ចំនួន ០១ គ្រឿង

– សម្ភារៈក្នុងផ្ទះ រួមមាន ម៉ាស៊ីនត្រជាក់ ០១ គ្រឿង ទូរទឹកកក ០១ គ្រឿង ម៉ាស៊ីនបោកខោអាវ ០១ គ្រឿង និងគ្រែឈើ រួមទាំងរបស់របរផ្សេងៗទៀត ។



Scanned with CamScanner

– តូបដែលមានទីតាំងនៅផ្សារសៀមរាប ឃុំសៀមរាប ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។

៥. ការអះអាងរបស់ចុងចម្លើយ

ចុងចម្លើយឈ្មោះ [redacted] វាសនា បានអះអាងថា: ខ្លួនសុំច្រានចោលការទាមទាររបស់ដើមចោទត្រង់ចំណុចទី១ ខ្លួនសូមបញ្ជាក់ថាទ្រព្យសម្បត្តិរួមដែលមានក្នុងពេលរួមរស់ជាមួយដើមចោទ គឺមានតែម៉ូតូចំនួន ០១ គ្រឿងម៉ាក PCX (បង់រំលោះ) តែប៉ុណ្ណោះ ។ ចំពោះដី និងផ្ទះល្វែង ១ ល្វែង ទទឹងប្រវែង ៣ ម៉ែត្រ និងបណ្ដោយប្រវែង ១៦ ម៉ែត្រ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១១០៥០១-០៥៣០ ចុះថ្ងៃទី ១២ ខែតុលា ឆ្នាំ២០២១ ចេញដោយសុរិយោដីខេត្តកណ្ដាល ទីតាំងស្ថិតនៅ ភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល ជាកម្មសិទ្ធរបស់ខ្លួន មិនមានចំណែកដើមចោទនោះទេ ដោយសារពេលទិញផ្ទះនេះខ្លួន បានឱ្យម្ដាយទៅខ្ចីប្រាក់គេដើម្បីយកមកបង់ ។ ប៉ុន្តែពេលទិញដី និងផ្ទះនោះខ្លួនបានដាក់ឈ្មោះគាត់ដែរ ដោយគិតថាគាត់ជាមនុស្សល្អអាចរស់នៅជាមួយគ្នាបាន ហើយសងលុយទៅម្ដាយគ្រប់ចំនួនវិញ។ ដូច្នេះ ខ្លួនស្នើសុំមានសិទ្ធិជាម្ចាស់ទ្រព្យលើដី និងផ្ទះមួយល្វែងដែលមានទទឹងប្រវែង ៣ម៉ែត្រ និងបណ្ដោយ១៦ម៉ែត្រ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១១០៥០១-០៥៣០ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ ចេញដោយសុរិយោដីខេត្តកណ្ដាល ដែលមានទីតាំងស្ថិតនៅ ភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល ។ ចំពោះម៉ាស៊ីនត្រជាក់ ម៉ាស៊ីនបោកខោអាវ ទូរទឹកកក ប្រសិនបើដើមចោទយល់ព្រមបញ្ចប់រឿងត្រឹមនេះ ខ្លួនព្រមប្រគល់ឱ្យតែម្ដង ។ ដោយឡែកគ្រែឈើ និងកុំព្យូទ័រមួយគ្រឿង ជាកម្មសិទ្ធិរបស់ខ្លួន ដូច្នេះខ្លួនមិនឯកភាពតាមការទាមទារ ។ ចំណែកតូបលក់ដូរលេខ J23 ដែលមានទីតាំងនៅផ្សារសៀមរាប ឃុំសៀមរាប ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ខ្លួនស្នើសុំបែងចែកជាពីរចំណែកស្មើគ្នា ។

៦. ឧស្សតាងជាឯកសាររួមមាន:

-ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍លេខ ៧២៣/១៥ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥ ។

-រូបថតចំនួន ០៩ សន្លឹក ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ ០២០៧៩៩៨៧៦(០១) (មួយច្បាប់ថតចម្លង) ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ ០២០៤៩៥៤៦៦(០១) (មួយច្បាប់ថតចម្លង) ។

-សៀវភៅស្នាក់នៅលេខ ០០០០៩៣ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២០ (មួយច្បាប់ថតចម្លង) ។

-កំណត់ហេតុលើកទី១ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២៣ (មួយច្បាប់ថតចម្លង) ។

-កំណត់ហេតុលើកទី២ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣ (មួយច្បាប់ថតចម្លង) ។

-USB ចំនួន ០១ (ជាសារសំលេង) ។

-តារាងសងប្រាក់ឥណទានជាលក្ខណៈបុគ្គល ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ (មួយច្បាប់ថតចម្លង) ។

-កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ (មួយច្បាប់ថតចម្លង) ។

-កិច្ចសន្យាបង្កើតហ៊ុប៊ូតែករួម លេខ ១៦០៥/១៩ (មួយច្បាប់ថតចម្លង) ។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១១០៥០១-០៥៣០ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ ចេញដោយសុរិយោដីខេត្តកណ្ដាល ។

-បណ្ណសម្គាល់យានយន្ត លេខ 1IE-3697 ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់ឈ្មោះ [redacted] សំណាង ។

ក្រោយពីបានស្ដាប់សេចក្ដីថ្លែងការណ៍របស់ភាគីដើមចោទ

ក្រោយពីបានស្ដាប់សេចក្ដីថ្លែងការណ៍របស់ភាគីចុងចម្លើយ

ក្រោយពីថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

## សំអាងហេតុ

១. ក្រោយពីបានធ្វើការសាកសួរភាគីដើមចោទ ធ្វើការផ្សះផ្សា និងធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់ តុលាការយល់ឃើញថា: គូភាគីពិតជាបានរួមរស់ជាមួយគ្នាជាប្តីប្រពន្ធពិតប្រាកដមែន ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ ដែលការរស់នៅជាមួយគ្នាមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នេះ គឺមិនមានអានុភាពគតិយុត្តជាប្តីប្រពន្ធស្របច្បាប់ឡើយ ។

២. តាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១១០៥០១-០៥៣០ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ ចេញដោយសុរិយោដីខេត្តកណ្តាល អាចបញ្ជាក់បានថា ដី និងផ្ទះមួយកន្លែងដែលមានទីតាំងស្ថិតនៅភូមិព្រែកហូរ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ពិតជាកម្មសិទ្ធិរបស់ដើមចោទឈ្មោះ [redacted] ម៉ាលីស និងចុងចម្លើយឈ្មោះ [redacted]វាសនា ប្រាកដមែន ។ តុលាការយល់ឃើញថា សិទ្ធិគ្រប់គ្រងដី និងផ្ទះមួយកន្លែងខាងលើ ភាគីដើមចោទ និងចុងចម្លើយបានគប្បីលក់ជាសាច់ប្រាក់ រួចចែកជាពីរចំណែកស្មើគ្នា ។

៣. តាមតារាងសងប្រាក់ឥណទានជាលក្ខណៈបុគ្គល ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១, កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែករួម លេខ ១៦០៥/១៩ ឃើញថាពិតជាមានឈ្មោះ [redacted] ម៉ាលីស ជាដើមចោទ និងឈ្មោះ [redacted]វាសនា ជាចុងចម្លើយ បានរួមគ្នាខ្ចីប្រាក់ពីធនាគារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតកាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ ចំនួន ១៥,៥០០ (មួយម៉ឺនប្រាំពាន់ប្រាំរយ) ដុល្លារអាមេរិក ប្រាកដមែន ។ គប្បីពិនិត្យ ពិចារណារ និងសម្រេច ។

៤. ចំពោះការទាមទារឱ្យតុលាការសម្រេចអំពីទ្រព្យរួមមាន:

៤.១. ម៉ូតូម៉ាក PCX សេរី ២០១១ ពាក់ស្លាកលេខ 1IE-3697 ចំនួន ០១ គ្រឿង ។

៤.២. កុំព្យូទ័រម៉ាក DELL ចំនួន ០១ គ្រឿង

៤.៣. សម្ភារៈក្នុងផ្ទះ រួមមាន ម៉ាស៊ីនត្រជាក់ ០១ គ្រឿង ទូរទឹកកក ០១ គ្រឿង ម៉ាស៊ីនបោកខោអាវ ០១ គ្រឿង និងគ្រែឈើ រួមទាំងរបស់របរផ្សេងៗទៀត ។

៤.៤. តូបដែលមានទីតាំងនៅផ្សារសៀមរាប ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

តុលាការយល់ថាមិនមានភស្តុតាងបញ្ជាក់អំពីទ្រព្យសម្បត្តិដែលភាគីដើមចោទ និងចុងចម្លើយបានអះអាងខាងលើនេះទេ គប្បីតុលាការមិនធ្វើការពិចារណា ។

៥. ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

## សេចក្តីសម្រេចបញ្ចប់

១. ច្រានចោលការទាមទារចំពោះការស្នើសុំឱ្យបែងចែកទ្រព្យសម្បត្តិរួមមាន: តូបដែលមានទីតាំងនៅផ្សារសៀមរាប ឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល, ម៉ូតូម៉ាក PCX សេរី ២០១១ ពាក់ស្លាកលេខ 1IE-3697 ចំនួន ០១ គ្រឿង, កុំព្យូទ័រម៉ាក DELL ចំនួន ០១ គ្រឿង, សម្ភារៈក្នុងផ្ទះ រួមមាន ម៉ាស៊ីនត្រជាក់ ០១ គ្រឿង ទូរទឹកកក ០១ គ្រឿង ម៉ាស៊ីនបោកខោអាវ ០១ គ្រឿង និងគ្រែឈើ រួមទាំងរបស់របរផ្សេងៗទៀត ។

២. ដី និងផ្ទះល្វែង ០១ ល្វែង មានទទឹងប្រវែង ០៣ ម៉ែត្រ និងបណ្តោយប្រវែង ១៦ ម៉ែត្រ មានទីតាំងស្ថិតនៅភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០៨១១០៥០១-០៥៣០ ចុះថ្ងៃទី ១២ ខែតុលា ឆ្នាំ២០២១ ចេញដោយសុរិយោដីខេត្តកណ្តាល ត្រូវបែងចែកឱ្យដើមចោទ និងចុងចម្លើយជាពីរចំណែកស្មើគ្នា ដោយលក់ជាសាច់ប្រាក់ ។



Scanned with CamScanner

៣. ឲ្យដើមចោទឈ្មោះ [redacted] ម៉ាលីស និងចុងចម្លើយឈ្មោះ [redacted] វាសនា រួមគ្នាសងប្រាក់ទៅធនាគារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹតតាមតារាងសងប្រាក់ឥណទានជាលក្ខណៈបុគ្គល ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់អស់។

៤. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ចំពោះមុខដើមចោទឈ្មោះ [redacted] ម៉ាលីស និងចុងចម្លើយឈ្មោះ [redacted] វាសនា ។

ទុកសិទ្ធិឲ្យគូភាគីប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ថ្ងៃពុធ ១១កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

កណ្ដាល, ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

"បានចម្លងត្រឹមត្រូវតាមសាលក្រមដើម"

ថ្ងៃពុធ ១១កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

កណ្ដាល, ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]



Scanned with CamScanner